ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករគណនេយ្យនិងសវនកម្ម

លេខ ០១០/២៥ ន. គ. ស/ស.ជ.ល.

ថ្ងៃព្រហ.៧រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមីនា គ.ស.២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដកហូតអាជ្ញាបណ្ណគណនេយ្យករម្រិត២ (នីតិបុគ្គល និងរូបវន្តបុគ្គល)

និយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) សូមជម្រាបជូនដំណឹងដល់ម្ចាស់សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ និងសាធារណជនជ្រាបថា៖ **ន.គ.ស.** បានសម្រេចដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យករម្រិត២ តាមសំណើសុំរបស់ម្ចាស់អាជ្ញាបណ្ណដូចខាងក្រោម៖

- ក្រុមហ៊ុន **ស្កាយលីមីធីត អឹខោនធីង (ខេមបូឌា) ខូ អិលធីឌី** ដែលមានលេខអាជ្ញាបណ្ណ ០០៧៤/២៤ ន.គ.ស.អ.ជ.គ២ (នីតិបុគ្គល)
- លោកស្រី ហេង ចាន់ណា ដែលមានអាជ្ញាបណ្ណលេខ ០១៤៤/២៤ ន.គ.ស.អ.ជ.គ២ (រូបវន្តបុគ្គល) គិតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥។

ដូច្នេះ **ន.គ.ស.** សូមជម្រាបដល់ម្ចាស់សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញនិងសាធារណជនដែលមានបំណងប្រើប្រាស់សេវាគណនេយ្យសូមធ្វើការផ្អាកឬ កុំប្រើប្រាស់សេវាគណនេយ្យ ដែលផ្តល់ដោយក្រុមហ៊ុន **ស្កាយលីមីធីត អឹខោនធីង (ខេមបូឌា) ខូ អិលធីឌី** ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ ដោយហេតុថាក្រុមហ៊ុនបានបាត់បង់នីតិសម្បទាក្នុងការផ្តល់សេវាគណនេយ្យ ដូចមានចែងក្នុងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

អាស្រ័យហេតុនេះ សូម ម្ចាស់សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ និងសាធារណជនជ្រាបជាព័ត៌មាន។

**និយ័តករគណនេយ្យនិងសវនកម្ម**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.

គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh

ទូរស័ព្ទ ៨៥៥ - ២៣ ៨៨២ ១១១
Phone: 023 882 111